# ព្រះរាជក្រម

នស/រកម/១២០៩/០២៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និង អាវុធវិទ្យុសកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

# ច្បាប់

# ស្តីពី

# ការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និង អាវុធវិទ្យុសកម្ម

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅហាមឃាត់ជាដាច់ខាតនូវការផលិត ការកែច្នៃ ការទទួល ការផ្ទេរ ការរក្សាទុក ការដឹកជញ្ជូន និងការប្រើប្រាស់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមីដែលទាក់ទងនឹងការផលិតអាវុធទាំងនេះ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះមានគោលបំណងធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការពារបរិស្ថាន សុខុមាលភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងរួមចំណែកការពារសន្តិសុខ និងសន្តិភាពក្នុងតំបន់ និង ពិភពលោក ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពទៅលើ :

- ប្រជាពលរដ្ឋខ្មែរ ទាំងក្នុងនិងទាំងក្រៅប្រទេស
- ជនបរទេសដែលបានចូល ឬ ស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ស្ថាប័ន គ្រឹះស្ថានសាធារណៈ មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ នៃព្រះរាជាណាចក្រកម្ពុជា
- ក្រុមហ៊ុន ឬ សាជីវកម្ម ឬ នីតិបុគ្គល ដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីមានសាខា ឬ បុត្រសម្ព័ន្ធ នៅក្នុង ឬ ក្រៅប្រទេសក៏ដោយ
- នាវា យន្តហោះ និងរាល់មធ្យោបាយដឹកជញ្ជូន ដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះនៅទីណាក៏ដោយ
- នាវា យន្តហោះ និងរាល់មធ្យោបាយដឹកជញ្ជូន ដែលបានចុះបញ្ជីនៅបរទេស ដែលធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

១- អាវុធគីមី សំដៅដល់ យុទ្ធោបករណ៍ ផលិតផលសម្រេច ដែលត្រូវបាន ផលិតឡើងដោយបំពាក់ នូវសារធាតុគីមី វិសេវផ្ទុះ និងក្បាលគ្រាប់ផ្ទុះ ។

២- អាវុធនុយក្លេអ៊ែរ សំដៅដល់ :

ក-អាវុធមហាប្រល័យគ្រប់ប្រភេទដែលអំណាចរបស់វាផ្ទុះដោយកម្លាំង បំបែកអាតូម បង្កឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិ ទ្រព្យសម្បត្តិ ឬ បរិស្ថាន ។

ខ-គ្រឿងផ្ទុះនុយក្លេអ៊ែរ ។

គ-គ្រឿងសម្រាប់សាយភាយវិទ្យុសកម្ម ឬគ្រឿងបញ្ចេញចុណ្ណភាគវិទ្យុ-សកម្ម ដោយសារសមាសធាតុវិទ្យុសកម្មរបស់វា ដែលបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ រុក្ខជាតិ ទ្រព្យសម្បត្តិ ឬ បរិស្ថាន ។

ឃ-ម៉ាស៊ីនប្រតិកម្មនុយក្លេអ៊ែរ សម្រាប់ប្រើជាប្រភពថាមពល ក្នុងគោល បំណងបង្កឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិ ទ្រព្យសម្បត្តិ ឬ បរិស្ថាន ។

ង-សារធាតុនុយក្លេអ៊ែរ ដែលត្រូវបានប្រើប្រាស់ក្នុងគោលបំណងបង្កឱ្យ មានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិ ទ្រព្យសម្បត្តិ ឬ បរិស្ថាន

ច-ឧបករណ៍ សម្ភារៈ ដែលត្រូវបានប្រើប្រាស់ក្នុងគោលបំណងកែច្នៃ ឬ បង្កើតអាវុធនុយក្លេអ៊ែរ ។

៣- អាវុធជីវសាស្ត្រ សំដៅដល់ :

ក-អាវុធមេរោគ ឬ ភ្នាក់ងារមេរោគ ដែលបង្កើតដោយអតិសុខុមប្រាណ ត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងបង្កឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិ ទ្រព្យសម្បត្តិ ឬ បរិស្ថាន ។

ខ-ឧបករណ៍ សម្ភារៈ សម្រាប់ប្រើប្រាស់ក្នុងការកែច្នៃ ឬ ផលិតអាវុធ មេរោគ ឬ ភ្នាក់ងារមេរោគ ដូចមានចែងនៅក្នុងវាក្យខណ្ឌ " ក " ខាងលើ ។

LE MINISTRE DU PALAIS ROYAL

៤- អាវុធវិទ្យុសកម្ម សំដៅដល់ ប្រភពវិទ្យុសកម្មដែលត្រូវបានប្រើប្រាស់ក្នុងគោលបំណងបង្កឱ្យមានគ្រោះ ថ្នាក់ដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិ ទ្រព្យសម្បត្តិ ឬបរិស្ថាន ។

៥- សារធាតុគីមី សំដៅដល់ :

ក- សារធាតុគីមី ឬ សារធាតុផ្សំទាំងឡាយណា ដែលប្រើសម្រាប់ផលិតអាវុធ ឬ ប្រើជាអាវុធ ក្នុងគោលបំណងបង្កឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្ស សត្វ រុក្ខជាតិ ទ្រព្យសម្បត្តិ ឬបរិស្ថាន ។

ខ- យុទ្ធោបករណ៍និងបរិធាននានា ដែលគេផលិតសម្រាប់បង្កឱ្យមានការស្លាប់ ឬ បង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ រុក្ខជាតិ ទ្រព្យសម្បត្តិ ឬ បរិស្ថាន ដោយសារជាតិពុលនៃសារធាតុគីមី ដែលបានបញ្ចេញដោយសារការប្រើប្រាស់យុទ្ធោបករណ៍ និង បរិធានទាំងនោះ ។

គ- បរិក្ខារទាំងឡាយណាដែលត្រូវបានគ្រោងជាពិសេស សម្រាប់ប្រើផ្ទាល់ជាមួយយុទ្ធោបករណ៍ និង បរិធាន ដែលមានចែងនៅក្នុងវាក្យខណ្ឌ " ខ " ខាងលើ ។

៦- បុគ្គល សំដៅដល់រូបវន្តបុគ្គល និងនីតិបុគ្គលដែលមិនមែនជាស្ថាប័នរដ្ឋ ។

## ជំពូកទី ២

## អាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

**មាត្រា ៥.-**

រាជរដ្ឋាភិបាលត្រូវបង្កើតអាជ្ញាធរជាតិមួយធ្វើជាតំណាងរបស់ខ្លួនដែលមានឈ្មោះថា " អាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម " ហៅកាត់ថា " អាជ្ញាធរជាតិអាវុធគីមី " ឬ " អ.ជ.អ.គ. " ។

**មាត្រា ៦.-**

អាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្មនេះ ត្រូវបង្កើតឡើងដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## ការហាមឃាត់

**មាត្រា ៧.–**

ការផលិត ការកែច្នៃ ការទទួល ការផ្ទេរ ការរក្សាទុក ការដឹកជញ្ជូនឆ្លងកាត់ និងការប្រើប្រាស់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ត្រូវហាមឃាត់ដាច់ខាត ។

**មាត្រា ៨.–**

ការផលិត ការកែច្នៃ ការទទួល ការផ្ទេរ ការរក្សាទុក ការដឹកជញ្ជូនឆ្លងកាត់ និងការប្រើប្រាស់សារធាតុគីមី ដែលទាក់ទងការផលិតអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ត្រូវហាមឃាត់ លើកលែងតែសារធាតុគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ដែលយកទៅប្រើប្រាស់ក្នុងវិស័យសុខាភិបាល ឧស្សាហកម្ម រ៉ែ ថាមពល កសិកម្ម ការស្រាវជ្រាវ និងគោលដៅសន្តិភាពផ្សេងទៀតដែលមានការអនុញ្ញាតពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា ៩.–**

សារធាតុគីមីដែលទាក់ទងនឹងការផលិតអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤
## ការឆែកឆេរ និងការចាប់យកវត្ថុតាង

**មាត្រា ១០.–**

មន្ត្រីអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម មានតួនាទីជាមន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញភារកិច្ចតាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌដែលជាធរមាន ។

**មាត្រា ១១.-**

ការឆែកឆេរនិងការចាប់យកវត្ថុតាងនៅទីកន្លែងដែលសង្ស័យថាមានរក្សាទុកនូវអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម អាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ និងមានដីកាតុលាការ មានសិទ្ធិឆែកឆេរគ្រប់ទីកន្លែងដែលសង្ស័យថាមានរក្សាទុកនូវអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម សារធាតុគីមី ដែលអាចផ្សំផលិតជាអាវុធទាំងនោះ ដែលពុំមានលិខិតអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច និងកាកសំណល់នៃសារធាតុខាងលើ ដែលនៅមានឥទ្ធិពលបង្កមហន្តរាយ ដើម្បីបង្ក្រាបចាប់យកវត្ថុតាង និងឃាត់ខ្លួនជនសង្ស័យប្រព្រឹត្តល្មើស ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១២.-**

រាល់វត្ថុតាងដែលចាប់យកបាន ត្រូវរក្សាទុកក្នុងឃ្លាំងសុវត្ថិភាពដែលគ្រប់គ្រងដោយអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ដើម្បីចាត់ចែងបែបបទធ្វើការបំផ្លាញចោល ឬ រក្សាទុកសម្រាប់ប្រើប្រាស់ក្នុងវិស័យសុខាភិបាល ឧស្សាហកម្ម រ៉ែ ថាមពល កសិកម្ម ការស្រាវជ្រាវ និង គោលដៅសន្តិភាពផ្សេងទៀត ។

## ជំពូកទី ៥

## ការបំផ្លាញ

**មាត្រា ១៣.-**

រាជរដ្ឋាភិបាលត្រូវបង្កើតឱ្យមានគណៈកម្មការអន្តរក្រសួងមួយ ដើម្បីរៀបចំនីតិវិធីបំផ្លាញចោលនូវអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារ-ធាតុគីមីដែលបានហាមឃាត់ទៅតាមបទដ្ឋានបច្ចេកទេស ។

**មាត្រា ១៤.-**

ក្នុងករណីចាំបាច់ នៅរាល់ការបំផ្លាញអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមីដែលទាក់ទងនឹងការផលិតអាវុធទាំងនេះ រាជរដ្ឋាភិបាល

អាចស្នើសុំអ្នកជំនាញបច្ចេកទេសពីអង្គការជាតិ និង អន្តរជាតិ ។

**មាត្រា ១៥.–**

រាល់វិធានការបំផ្លាញ ដូចមានចែងនៅក្នុងមាត្រា១៣ និង មាត្រា១៤ នៃច្បាប់នេះ ត្រូវគោរពគោលការណ៍សុវត្ថិភាព សន្តិសុខ និងបរិស្ថាន ។

## ជំពូកទី ៦
## គោលនយោបាយ និងផែនការសកម្មភាព

**មាត្រា ១៦.–**

អាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និង វិទ្យុសកម្ម ត្រូវរៀប គោលនយោបាយ និងផែនការសកម្មភាព ទាក់ទងនឹងការហាមឃាត់និងទប់ស្កាត់អាវុ គីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមី ដែលអាចផ្សំសម្រា ផលិតអាវុធទាំងនេះ ដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ សង្គមស៊ីវិល អង្គកា ជាតិ និងអន្តរជាតិនានា ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**មាត្រា ១៧.–**

រាល់គោលនយោបាយ និងផែនការសកម្មភាព ត្រូវធានាថានៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គ្មានអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និង គ្មានសារធាតុគីមីដែលបានហាមឃាត់ ។

## ជំពូកទី ៧
## ការអប់រំ និងការផ្សព្វផ្សាយ

**មាត្រា ១៨.–**

អាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ត្រូវធ្វើការអប់ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយតាមគ្រប់មធ្យោបាយ ដោយគិតទាំងសិក្ខាសាលា កម្មវិ ត្តូម្ហ៍ និងវេទិកាផ្សេងៗ អំពីការហាមឃាត់ ផលប៉ះពាល់ និងគ្រោះថ្នាក់ដែលបណ្តាលមក ពីអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមីដែលអាច ផ្សំសម្រាប់ផលិតអាវុធទាំងនេះ ។

**មាត្រា ១៩.-**

ក្រសួងទទួលបន្ទុកវិស័យព័ត៌មាន ត្រូវចូលរួមសហការយ៉ាងសកម្ម ក្នុងការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដូចមានចែងក្នុងមាត្រា ១៨ នៃច្បាប់នេះ តាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងប្រព័ន្ធផ្សព្វផ្សាយឯកជន ។

## ជំពូកទី ៨
## ការប្រមូលទិន្នន័យ និងការវាយតម្លៃ

**មាត្រា ២០.-**

ទិន្នន័យសម្ងាត់ស្តីពីអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមីដែលទាក់ទងនឹងការផលិតអាវុធទាំងនេះ និងព័ត៌មានសម្ងាត់ផ្សេងទៀត ដែលផ្តល់ឱ្យ ឬ ទទួលបានស្របតាមច្បាប់នេះ ឬ តាមអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ដែលត្រូវបានអនុវត្តតាមរយៈច្បាប់នេះ ត្រូវទុកជាការសម្ងាត់ ។

**មាត្រា ២១.-**

មានតែអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្មទេ ដែលមានសិទ្ធិប្រមូលវាយតម្លៃ និងផ្សព្វផ្សាយអំពីទិន្នន័យ និងព័ត៌មាន អាវុធគីមី អាវុធនុយក្លេ-អ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមីដែលពាក់ព័ន្ធនឹងការផលិតអាវុធខាងលើ នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៩
## មន្ទីរពិសោធន៍ និងស្ថានីយត្រួតពិនិត្យ

**មាត្រា ២២.-**

អាជ្ញាធរជាតិទប់ស្កាត់អាវុធគីមី នុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម ត្រូវរៀបចំឱ្យមានមន្ទីរពិសោធន៍ និងស្ថានីយត្រួតពិនិត្យអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមីដែលទាក់ទងនឹងការផលិតអាវុធទាំងនេះ នៅតាមទីតាំងដែលសមស្របនិងចាំបាច់ ។

**មាត្រា ២៣.-**

ការរៀបចំបណ្តាញស្ថានីយត្រួតពិនិត្យអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមីដែលទាក់ទងនឹងការផលិតអាវុធទាំងនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ១០
## ការអនុវត្តអនុសញ្ញាអន្តរជាតិ និងសហប្រតិបត្តិការ

**មាត្រា ២៤.-**

បទប្បញ្ញត្តិនៃអនុសញ្ញាអន្តរជាតិទាំងឡាយណា ដែលទាក់ទងនឹងការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ដែលព្រះរាជាណាចក្រកម្ពុជា ជារដ្ឋភាគី ត្រូវយកមកអនុវត្តជាមួយច្បាប់នេះ ។

ករណីមានទំនាស់ជាមួយនឹងបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ បទប្បញ្ញត្តិនៃអនុសញ្ញាអន្តរជាតិទាំងនោះ ត្រូវចាត់ទុកជាបទប្បញ្ញត្តិគោល ។

**មាត្រា ២៥.-**

ព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើសហប្រតិបត្តិការជាមួយអង្គការ ឬ រដ្ឋជាភាគីនៃអនុសញ្ញាអន្តរជាតិនានា ដែលទាក់ទងទៅនឹងការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ដោយឈរលើគោលការណ៍សមភាព និងគោរពអធិបតេយ្យ ស្របតាមអនុសញ្ញាអន្តរជាតិ ។

## ជំពូកទី ១១
## ទោសប្បញ្ញត្តិ

**មាត្រា ២៦.-**

បុគ្គលដែលផលិត កែច្នៃ ទទួល ផ្ទេរ រក្សាទុក ដឹកជញ្ជូនឆ្លងកាត់ ឬ ប្រើប្រាស់ដោយចេតនានូវអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬ អស់មួយជីវិត ។

**មាត្រា ២៧.—**

បុគ្គលដែលផលិត កែច្នៃ ទទួល ផ្ទេរ រក្សាទុក ដឹកជញ្ជូនឆ្លងកាត់ ឬ ប្រើប្រាស់សារធាតុគីមីដែលយកទៅផលិតអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

**មាត្រា ២៨.—**

បុគ្គលដែលផលិត ទិញ លក់ កាន់កាប់ កែច្នៃ ទទួល ផ្ទេរ រក្សាទុក ដឹកជញ្ជូនឆ្លងកាត់ ឬ ប្រើប្រាស់សារធាតុគីមីដែលយកទៅប្រើក្នុងវិស័យសុខាភិបាល ឧស្សាហកម្ម រ៉ែ ថាមពល កសិកម្ម និងការស្រាវជ្រាវ ក្នុងគោលដៅសន្តិភាពផ្សេងទៀត ដោយគ្មានលិខិតអនុញ្ញាតពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ។

**មាត្រា ២៩.—**

បុគ្គលដែលបានផ្សព្វផ្សាយព័ត៌មានអំពីទិន្នន័យអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម ដោយពុំមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។

**មាត្រា ៣០.—**

នីតិបុគ្គល ដែលត្រូវបានចាត់ទុកថាបានប្រព្រឹត្តបទល្មើសប្រឆាំងនឹងច្បាប់នេះ ដោយចេតនា ឬ ដោយដឹងខ្លួន ប្រសិនបើខ្លួនបានអនុញ្ញាត ឬ យល់ព្រមដោយផ្ទាល់ ឬ ដោយប្រយោលចំពោះការប្រព្រឹត្តបទល្មើសនោះ ហើយប្រសិនបើនីតិបុគ្គលនោះដែលត្រូវបានសម្រេចឱ្យជាប់ទោសចំពោះបទល្មើសប្រឆាំងនឹងច្បាប់នេះ តុលាការត្រូវកំណត់ពិន័យជាប្រាក់ជំនួសឱ្យរយៈពេលជាប់ពន្ធនាគារ ដោយអនុលោមតាមកថាខណ្ឌខាងក្រោមនេះ :

-ការពិន័យជាប្រាក់សម្រាប់នីតិបុគ្គលគឺ ២.០០០.០០០ (ពីរលាន) រៀល សម្រាប់រយៈពេលជាប់ពន្ធនាគារចំនួន ១២ (ដប់ពីរ) ខែ ដែលតុលាការនឹងដាក់លើនីតិបុគ្គលនោះ ប្រសិនបើនីតិបុគ្គលនោះជារូបវន្តបុគ្គល ។

-បន្ថែមលើការពិន័យជាប្រាក់ តុលាការអាចដាក់ទោសបន្ថែមណាមួយថែម

ទៀត ដូចខាងក្រោម ៖

ក-រំលាយនីតិបុគ្គល ។

ខ-ដាក់ឱ្យនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ។

## ជំពូកទី ១២

## អន្តរប្បញ្ញត្តិ

**មាត្រា ៣១.-**

ក្រោយពីច្បាប់នេះ ចូលជាធរមានក្នុងរយៈពេល ៣ (បី) ខែ រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានរក្សាទុកសារធាតុគីមី ទាក់ទងនឹងការផលិតអាវុធគីមី អាវុធនុយក្លេអ៊ែរ អាវុធជីវសាស្ត្រ អាវុធវិទ្យុសកម្ម និងសារធាតុគីមីដែលគ្មានលិខិតអនុញ្ញាត ត្រូវមករាយការណ៍ជូន ឬ ប្រគល់ជូនស្ថាប័នមានសមត្ថកិច្ច ។

ករណីមិនផ្តល់ព័ត៌មាន ឬ មិនប្រគល់ជូន ត្រូវផ្តន្ទាទោសតាមជំពូកទី ១១ នៃច្បាប់នេះ ។

## ជំពូកទី ១៣

## អវសានប្បញ្ញត្តិ

**មាត្រា ៣២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩

នស/រកម.០៩១២.០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

**ហត្ថលេខា**

**ទៀ បាញ់**

លេខ :១០៥៤ច.ល

ថតចម្លងចេញ

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឌិន កេន

13/13